# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១៖ រំហូរការងារសម្រាប់រៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

## ▪ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរាជធានី ខេត្ត (CPDP)

**ជំហានទី១៖ ការរៀបចំនិងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

- ១.១ ការរៀបចំឯកសារ និងព័ត៌មាន
  - ១.១.១ ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - ១.១.២ ការរៀបចំតារាងវិភាគស្ថានភាពរាជធានី ខេត្ត
  - ១.១.៣ ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត
  - ១.១.៤ ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា
- ១.២ កិច្ចប្រជុំដើម្បីផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ជំហានទី២៖ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

- ២.១ កិច្ចប្រជុំពេញអង្គស្តីពីការវិភាគស្ថានភាពរាជធានី ខេត្ត និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត
- ២.២ ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត
- ២.៣ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ២.៤ ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ២.៥ ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ២.៦ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាល លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
- ២.៨ ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

**ជំហានទី ៣ ៖ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានី ខេត្ត**

- ៣.១ ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត
  - ៣.១.១ ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត
  - ៣.១.២ កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត
  - ៣.១.៣ ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត
- ៣.២ ការបោះពុម្ពនិងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានីខេត្ត
  - ៣.២.១ ការបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រាជធានីខេត្ត
  - ៣.២.២ ការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

## ▪ កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត (CPIP)

**ជំហានទី១៖ ការរៀបចំគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- ១.១ ការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច
- ១.២ កិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ
- ១.៣ ការពិនិត្យសំណើគម្រោងវិនិយោគ
- ១.៤ កិច្ចប្រជុំពិនិត្យតារាងបូកសរុបសំណើគម្រោងវិនិយោគ

**ជំហានទី២៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- ២.១ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.២ ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.៣ សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.៤ ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគរាជធានីខេត្ត
- ២.៥ ផែនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ២.៦ ការរៀបចំបញ្ចប់លើសេចក្តីព្រាងចុងក្រោយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.៧ ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត
- ២.៨ ការពិនិត្យនិងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួល

**ជំហានទី៣៖ ការអនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត**

- ៣.១ ការអនុម័តផែនការអភិវឌ្ឍន៍
  - ៣.១.១ ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានីខេត្ត
  - ៣.១.២ កិច្ចប្រជុំក្រុមប្រឹក្សារាជធានីខេត្ត
  - ៣.១.៣ ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត
- ៣.២ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

## ឧបសម្ព័ន្ធ ២៖ ឧបករណ៍វិភាគ

ផ្នែកនេះ ពន្យល់ពីឧបករណ៍វិភាគមួយចំនួន ដែលអាចយកទៅប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពសម្រាប់ការវិភាគស្ថានភាព និងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍។

### ឧបសម្ព័ន្ធ ២.១ ការវិភាគបញ្ហា

អ្នកពាក់ព័ន្ធនានា នឹងត្រូវចូលរួមវិភាគបញ្ហានាពេលបច្ចុប្បន្នទាក់ទងទៅនឹងផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកបរិស្ថាន និងផ្នែកផ្សេងៗទៀតសម្រាប់ "ការវិភាគស្ថានភាព"។ វិធីសាស្ត្រវិភាគបញ្ហាត្រូវបាន ស្នើសម្រាប់ការវិភាគស្ថានភាព ដោយសារ វិធីសាស្ត្រនេះ អាចវិភាគពីទំនាក់ទំនង ហេតុ និងផលរវាងបញ្ហាជាច្រើនប្រកបដោយប្រសិទ្ធភាព។

<u>ដំណើរការវិភាគបញ្ហា</u>

១. កំណត់ និងកត់ត្រាបញ្ហានានានៃផ្នែកនីមួយៗនៅលើក្រដាសតូចដែលអ្នកពាក់ព័ន្ធគិតថាមានសារៈសំខាន់។
   ***សម្គាល់៖*** *ក្នុងការងារជាក្រុម ការប្រើប្រាស់ក្រដាសពណ៌បិទចំណាំតូចៗ ក្តារខៀន និងក្រដាសផ្ទាំងធំបិទលើជញ្ជាំងកាន់តែប្រសើរ។*

២. ព្យាយាមបង្កើតដើមឈើបញ្ហាមួយ ដោយផ្អែកលើភាពសមហេតុផលនៃទំនាក់ទំនងរវាងមូលហេតុ និងផលប៉ះពាល់ ។
   ***សម្គាល់៖*** *សូមមើលឧទាហរណ៍គំរូនៃដើមឈើបញ្ហាអំពី "ការផ្គត់ផ្គង់ទឹកស្អាត" ។*

៣. កំណត់បញ្ហាមួយដែលគ្របដណ្តប់បញ្ហាជាច្រើន ហើយអ្នកពាក់ព័ន្ធចង់ធ្វើការដោះស្រាយក្នុងរយៈពេលប្រាំ (០៥)ឆ្នាំ ។ បញ្ហានេះហៅថា "បញ្ហាស្នូល" ។
   ***សម្គាល់៖*** *ស្នើសូម <u>ជ្រើសរើសបញ្ហាស្នូលតែពីរ(០២) ឬបី(០៣)</u> សម្រាប់ផ្នែកនីមួយៗ ដោយសារធនធានក្នុងរាជធានី ខេត្ត នៅមានកម្រិត ។*

៤. កំណត់មូលហេតុនានាដែលនាំទៅរកបញ្ហាស្នូល។ មូលហេតុទាំងនេះហៅថា "មូលហេតុផ្ទាល់"។
   ***សម្គាល់៖*** *មូលហេតុផ្ទាល់ នាំទៅរកបញ្ហាស្នូលដែលអាចបណ្តាលមកពីមូលហេតុច្រើនជាងមួយ ។*

៥. កំណត់មូលហេតុនានាដែលនាំទៅរក"មូលហេតុផ្ទាល់"។ មូលហេតុនានាទាំងនេះ ហៅថា "មូលហេតុរង"។

៦. ត្រួតពិនិត្យមើល ថាតើបញ្ហាយេនឌ័រដែលមើលរំលងកើតមានចំពោះបញ្ហាស្នូល ឬមូលហេតុផ្ទាល់ដែរឬទេ (ឧទាហរណ៍៖ ភាពមិនស្មើគ្នាក្នុងការទទួលបានសេវាហិរញ្ញវត្ថុរវាងបុរស និងស្ត្រី)។ ប្រសិនបើ មានបញ្ហាយេនឌ័រមិនស្មើគ្នាធ្ងន់ធ្ងរ សូមសរសេរនៅលើក្រដាសតូច ហើយដាក់បញ្ហានេះខាងក្រោមបញ្ហាពាក់ព័ន្ធរបស់វា។

**គំនូសតាង៖ ឧទាហរណ៍នៃការវិភាគបញ្ហាក្នុងការផ្គត់ផ្គង់ទឹកស្អាត**




**ឧបសម្ព័ន្ធ ២.២ ការវិភាគរកដំណោះស្រាយ**

អ្នកពាក់ព័ន្ធត្រូវចូលរួមធ្វើការវិភាគគោលបំណង គោលដៅ និងដំណោះស្រាយនៅក្នុងផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកបរិស្ថាន និងផ្នែកផ្សេងៗទៀត។ ក្នុងចំណុចនេះ ការវិភាគរកដំណោះស្រាយ គឺជាឧបករណ៍វិភាគប្រកបដោយប្រសិទ្ធភាពក្នុងការរៀបចំ "ក្របខ័ណ្ឌអភិវឌ្ឍន៍" ដោយសារតែការវិភាគនេះ រៀបចំឡើងដោយផ្អែកលើ ក )លទ្ធផលនៃការវិភាគបញ្ហា និង ខ )ការគិតគូរដ៏សមហេតុផលនៃទំនាក់ទំនងរវាងមធ្យោបាយ និងលទ្ធផល ។

<u>ដំណើរការវិភាគរកដំណោះស្រាយ</u>

១. បំប្លែងឃ្លា "បញ្ហាស្នូល" ជា "គោលបំណង" ដោយការប្តូរប្រយោគអវិជ្ជមាន ទៅជាស្ថានភាពវិជ្ជមាន ដែលក្នុងនោះបញ្ហាស្នូលត្រូវបានដោះស្រាយ ។
២. បំប្លែងឃ្លា "មូលហេតុផ្ទាល់" ជា "គោលដៅ" តាមវិធីដូចគ្នាខាងលើ ។
៣. បំប្លែងឃ្លា "មូលហេតុរង" ជា "ដំណោះស្រាយ (សកម្មភាពនានា)" តាមវិធីដូចគ្នា ។

**សម្គាល់៖** ក្នុងករណីខ្លះ បញ្ហានិងមូលហេតុខ្លះៗមិនអាចបំប្លែងជាគោលបំណង គោលដៅនិង ដំណោះស្រាយបានទេ។ ឧទាហរណ៍៖ បញ្ហា **"មានភ្លៀងធ្លាក់តិចក្នុងតំបន់នេះ"** មិនអាចប្តូរទៅជា "មានភ្លៀងធ្លាក់ច្រើនក្នុងតំបន់នេះ"បានទេ
នេះគឺដោយសារខេត្តមិនមានលទ្ធភាពក្នុងការបង្កើន បរិមាណភ្លៀងធ្លាក់ដោយបច្ចេកវិទ្យា។ ក្នុងករណីកាតដែលពីបង្ហាញពី"លទ្ធភាពតិចតួច" ក្នុង ការសម្រេចបានបែបនេះ

មិនគួរយកចិត្តទុកដាក់ ឬគេអាចប្តូរទៅជាប្រយោគវិជ្ជមានដូចជា "បច្ចេកវិទ្យាប្រើប្រាស់ទឹកដោយសន្សំសំចៃត្រូវបានណែនាំឱ្យប្រើ។

**គំនូសតាង៖ ឧទាហរណ៍នៃការវិភាគរកដំណោះស្រាយក្នុងការផ្គត់ផ្គង់ទឹកស្អាត**




**ឧបសម្ព័ន្ធ ២.៣ ការវិភាគ SWOT**

ការវិភាគSWOT ត្រូវបានណែនាំឱ្យប្រើប្រាស់ ក )ឧបករណ៍វិភាគសម្រាប់រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ និង ខ )ឧបករណ៍វិភាគបំពេញបន្ថែមសម្រាប់ការរៀបចំ "ក្របខ័ណ្ឌអភិវឌ្ឍន៍"។ SWOT សិក្សា និងវិភាគទៅលើ ១ )កត្តាខាងក្នុងនៅក្នុងវិស័យ/អង្គភាពជាក់លាក់មួយ និង ២ )កត្តាខាងក្រៅដែលកើតមានពីខាងក្រៅវិស័យ/អង្គភាពនោះ។ ឧបករណ៍នេះ ជួយអ្នកពាក់ព័ន្ធនានាឱ្យយល់ពីការវិភាគទាំងកត្តាខាងក្រៅ និងកត្តាខាងក្នុងនៅពេលតែមួយ ព្រមទាំងរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ដែលមានយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយភាពប្រាកដនិយម។

<u>ក. ដំណើរការវិភាគ SWOT សម្រាប់រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ</u>

១. ពិនិត្យឯកសារពាក់ព័ន្ធដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងឯកសារផ្សេងទៀត មុនធ្វើការវិភាគSWOT។

២. ពិភាក្សា និងកំណត់កត្តាខាងក្នុង(កត្តានៅក្នុងរាជធានី ខេត្ត និងវិស័យនានា) ពីភាពខ្លាំង និងភាពខ្សោយនៃរាជធានី ខេត្ត។

៣. ពិភាក្សា និងកំណត់កត្តាខាងក្រៅអំពីឱកាស និងការគំរាមកំហែង(កត្តាខាងក្រៅរាជធានី ខេត្ត និងវិស័យនានា)

៤. ប្រសិនបើមានកត្តានានាច្រើនជាង៥នៅក្នុង ៤ប្រភេទផ្សេងៗគ្នា (ភាពខ្លាំង ភាពខ្សោយ ឱកាស ការគំរាមកំហែង) សូមព្យាយាមជ្រើសរើសកត្តាដែលសំខាន់ជាងគេបំផុតចំនួនបី(០៣)ជាអតិបរិមាដើម្បីងាយស្រួលក្នុងការពិភាក្សា ។

៥. សូមបង្កើតនូវយុទ្ធសាស្ត្រនានាដោយរួមបញ្ចូល ១)កត្តាខាងក្នុង(ភាពខ្លាំង និងភាពខ្សោយ) និង ២)កត្តាខាងក្រៅ( ឱកាស និងការគំរាមកំហែង) ដោយផ្អែកលើការរួមបញ្ចូលគ្នាដូចខាងក្រោម៖

- **ឱកាស និងភាពខ្លាំង៖** តើរាជធានី ខេត្ត អាចប្រើប្រាស់ឱកាសដែលមិនបានប្រើប្រាស់ពីមុន ដើម្បីប្រើប្រាស់ភាពខ្លាំងរបស់រាជធានី ខេត្ត តាមរបៀបណា?
- **ឱកាស និងភាពខ្សោយ៖** តើរាជធានី ខេត្ត អាចប្រើប្រាស់ឱកាសដែលមិនបានប្រើប្រាស់ពីមុនដើម្បីកាត់បន្ថយភាពខ្សោយដែលជាឧបសគ្គនៃការប្រើប្រាស់ឱកាសយ៉ាងដូចម្តេច ?
- **ការគំរាមកំហែង និងភាពខ្លាំង៖** តើរាជធានី ខេត្ត អាចពុះពារពីការគំរាមកំហែងដោយការប្រើប្រាស់ភាពខ្លាំងយ៉ាងដូចម្តេច ?
- **ការគំរាមកំហែង និងភាពខ្សោយ៖** តើរាជធានី ខេត្តអាចពុះពារពីការគំរាមកំហែងដោយកាត់បន្ថយភាពខ្សោយរបៀបណា ?

៦. ពិនិត្យសេចក្តីព្រាងយុទ្ធសាស្ត្រនានា និងជ្រើសរើសយុទ្ធសាស្ត្រដែលជាក់ស្តែងនិងមានប្រសិទ្ធភាពជាងគេបំផុត។

៧. រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយដូចទម្រង់គំរូខាងលើ។

<u>**ខ. ដំណើរការវិភាគ SWOT សម្រាប់រៀបចំក្របខ័ណ្ឌអតិទិន្នន័**</u>

១. ពិភាក្សា និងកំណត់កត្តាខាងក្នុង(កត្តានៅក្នុងរាជធានី ខេត្ត និងវិស័យនានា) ពីភាពខ្លាំង និងភាពខ្សោយដែលទាក់ទងនឹងផ្នែកជាក់លាក់ណាមួយ។

២. ពិភាក្សា និងកំណត់កត្តាខាងក្រៅ(កត្តាខាងក្រៅរាជធានី ខេត្ត និងវិស័យនានា ) អំពីឱកាស និង ការគំរាមកំហែងទាក់ទងនឹងផ្នែកជាក់លាក់ណាមួយ

៣. ប្រសិនបើមានកត្តានានាច្រើនជាងប្រាំនៅក្នុងបួនប្រភេទផ្សេងៗគ្នា(ភាពខ្លាំង ភាពខ្សោយ ឱកាស ការគំរាមកំហែង) សូមព្យាយាមជ្រើសរើសកត្តាដែលសំខាន់ជាងគេបំផុតចំនួនបី(០៣)ជាអតិបរិមាក្នុងមួយប្រភេទដើម្បីងាយស្រួលក្នុងការពិភាក្សា ។

៤. សូមបង្កើតនូវយុទ្ធសាស្ត្រនានាដោយរួមបញ្ចូល ១)កត្តាខាងក្នុង(ភាពខ្លាំង និងភាពខ្សោយ) និង ២)កត្តាខាងក្រៅ (ឱកាស និងភាពគំរាមកំហែង) ដោយផ្អែកលើការរួមបញ្ចូលគ្នាដូចខាងក្រោម៖

- **ឱកាស និងភាពខ្លាំង៖** តើរាជធានី ខេត្ត អាចប្រើប្រាស់ឱកាសដែលមិនបានប្រើប្រាស់ពីមុន ដើម្បីប្រើប្រាស់ភាពខ្លាំងរបស់រាជធានី ខេត្ត តាមរបៀបណា?
- **ឱកាស និងភាពខ្សោយ៖** តើរាជធានី ខេត្ត អាចប្រើប្រាស់ឱកាសដែលមិនបានប្រើប្រាស់ពីមុនដើម្បីកាត់បន្ថយភាពខ្សោយដែលជាឧបសគ្គនៃការប្រើប្រាស់ឱកាសយ៉ាងដូចម្តេច ?
- **ការគំរាមកំហែង និងភាពខ្លាំង៖** តើរាជធានី ខេត្ត អាចពុះពារពីការគំរាមកំហែង ដោយការប្រើប្រាស់ភាពខ្លាំងយ៉ាងដូចម្តេច ?

- **ការគំរាមកំហែង និងភាពខ្សោយ៖** តើរាជធានី ខេត្ត អាចពុះពារពីការគំរាមកំហែង ដោយកាត់បន្ថយភាពខ្សោយរបៀបណា ?

៥. ពិនិត្យសេចក្តីព្រាងយុទ្ធសាស្ត្រនានា និងជ្រើសរើសយុទ្ធសាស្ត្រដែលជាក់ស្តែង និងមានប្រសិទ្ធភាពជាងគេបំផុត។

**និយមន័យនៃភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង**

| | |
|---|---|
| ភាពខ្លាំង | បុគ្គលិកលក្ខណៈនៃរាជធានី ខេត្ត និងវិស័យដែលផ្តល់ផលប្រយោជន៍ដល់រាជធានី ខេត្តនោះ។ **ឧទាហរណ៍៖** ខេត្តមានព្រៃឈើសមស្របសម្រាប់អេកូទេសចរណ៍។ |
| ភាពខ្សោយ | បុគ្គលិកលក្ខណៈដែលធ្វើឱ្យរាជធានីខេត្ត និងវិស័យដែលផ្តល់នូវគុណវិបត្តិដល់រាជធានី ខេត្តនោះ។ **ឧទាហរណ៍៖** ខេត្តមិនមានប្រព័ន្ធផ្លូវល្អឆ្ពោះទៅកាន់រាជធានីភ្នំពេញ។ |
| ឱកាស | ឱកាសពីបរិស្ថានខាងក្រៅ ដែលធ្វើឱ្យមានការអភិវឌ្ឍ និងផលប្រយោជន៍ដ៏ធំធេងចំពោះរាជធានី ខេត្ត។ **ឧទាហរណ៍៖** វិស័យអេកូទេសចរណ៍ កំពុងត្រូវបានពិភពលោកយកចិត្តទុកដាក់ជាខ្លាំង។ |
| ការគំរាមកំហែង | ជាតុផ្សំនានាពីបរិស្ថានខាងក្រៅដែលបណ្តាលឱ្យមានបញ្ហាដល់រាជធានី ខេត្ត និងវិស័យ។ **ឧទាហរណ៍៖** រមណីយដ្ឋានដែលគួរឱ្យទាក់ទាញជាច្រើនមាននៅក្នុងប្រទេសកម្ពុជា ក៏ដូចជាប្រទេសជិតខាងដែរ។ |

ប្រភព៖ ដកស្រង់ពី http://en.wikipedia.org/wiki/SWOT_analysis

ទោះបីSWOT ជាឧបករណ៍វិភាគប្រកបដោយប្រសិទ្ធភាព អ្នកវិភាគត្រូវធ្វើការកត់សម្គាល់នូវចំណុចមួយចំនួនដើម្បីរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ ។

- វិធីសាស្ត្រនៃការវិភាគ រៀបចំឡើងដោយមានលក្ខណៈខុសប្លែកគ្នាគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖ ១)ការបូកបូកបញ្ចូលគ្នារវាងការវិភាគបញ្ហា និងការវិភាគដំណោះស្រាយ និង ២)ការវិភាគ SWOT

| ឧបករណ៍ | ចរិតលក្ខណ: |
|---|---|
| ការវិភាគបញ្ហា និង ការវិភាគដំណោះស្រាយ | ▪ ការវិភាគទាំង២ ធ្វើឡើងដោយផ្អែកលើទំនាក់ទំនងរវាងហេតុ និងផលការវិភាគបញ្ហាផ្អែកលើទំនាក់ទំនងរវាង "**មូលហេតុ និងផលប៉ះពាល់**" រីឯការវិភាគដំណោះស្រាយផ្អែកលើទំនាក់ទំនងរវាង"**មធ្យោបាយ និងលទ្ធផល**"។<br>▪ ការវិភាគបញ្ហាផ្តោតតែលើចំណុចអវិជ្ជមាន<br>▪ ការវិភាគបញ្ហា និងការវិភាគដំណោះស្រាយមិនបានបែងចែកភាពខុសគ្នារវាងកត្តាខាងក្នុង (ស្ថិតក្នុងរាជធានី ខេត្ត) និងកត្តាខាងក្រៅ (ស្ថិតក្រៅរាជធានី ខេត្ត)។ |
| ការវិភាគ SWOT | ▪ ការវិភាគ SWOT មិនប្រើប្រាស់ទំនាក់ទំនងរវាងហេតុ និងផល<br>▪ ការវិភាគSWOT ផ្តោតលើចំណុចវិជ្ជមាន(ឧទាហរណ៍៖ភាពខ្លាំង |

| | |
|---|---|
| | និងឱកាស) និងចំណុចអវិជ្ជមាន (ឧទាហរណ៍៖ ភាពខ្សោយ និងការគំរាមកំហែង)<br>▪ ការវិភាគ SWOT បែងចែកយ៉ាងច្បាស់រវាងកត្តាខាងក្នុង (ស្ថិតក្នុងរាជធានី ខេត្ត) និងកត្តាខាងក្រៅ (ស្ថិតក្រៅរាជធានី ខេត្ត)។ |

- ការវិភាគ SWOT មិនប្រើទំនាក់ទំនងហេតុ និងផល និងមិនសូវសមស្របសម្រាប់ "តារាងវិភាគស្ថានភាព" និង "តារាងក្របខ័ណ្ឌអភិវឌ្ឍន៍"ទេ ។ ឧទាហរណ៍ស្តីពីសុខភាពកុមារបង្ហាញថា *មណ្ឌលសុខភាពបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តគាំពារសុខភាពសហគមន៍សម្រាប់ផ្តល់សេវាកម្មព្យាបាលឱ្យបាន ទូលំទូលាយ* ជាយុទ្ធសាស្ត្រមួយដែលបូកបញ្ចូល "ភាពខ្លាំង" និង"ឱកាស" ដែលចាត់ទុកថាជា ដំណោះស្រាយ ប៉ុន្តែវាមិនបានបញ្ជាក់ច្បាស់លាស់ពីគោលបំណង និងគោលដៅដែលអាចសម្រេច បានតាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រនេះទេ។ ដូច្នេះ ការវិភាគSWOT អាចប្រើប្រាស់សម្រាប់ការ វិភាគបន្ថែមក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ពីគោលបំណង និងគោលដៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍។
- ទោះបីជាមានការលំបាកមួយចំនួន ក្នុងការប្រើប្រាស់លទ្ធផលនៃការវិភាគSWOT ដើម្បីបំពេញក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ ឧបករណ៍វិភាគនេះមានប្រយោជន៍ក្នុងការវិភាគអំពីចំណុចវិជ្ជមានរបស់រាជធានី ខេត្តដែរ។

ឧទាហរណ៍៖ ការវិភាគ SWOT ករណីសុខភាពកុមារ

| ឧទាហរណ៍៖<br>សេវាសុខភាពសម្រាប់កុមាររបស់មណ្ឌលសុខភាព | ឱកាស<br>១. មានក្រុមជំនួយក្នុងការអនុវត្តសកម្មភាពនានារបស់មណ្ឌលសុខភាព។ | ភាពគំរាមកំហែង<br>១. ឪពុកម្តាយមួយចំនួន មិនបានយល់ដឹងពីសារៈសំខាន់នៃការថែទាំសុខភាពកុមារ ។ |
|---|---|---|
| ភាពខ្លាំង<br>១. ធនធានមនុស្សក្នុងមណ្ឌលសុខភាពមានសមត្ថភាពខ្ពស់ដោយសារមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍនានា ។<br>២. ការផ្គត់ផ្គង់ថ្នាំបង្ការបានគ្រប់គ្រាន់ និងទាន់ពេលវេលា។ | ប្រើប្រាស់ឱកាសដោយប្រើប្រាស់ភាពខ្លាំង<br>១. មណ្ឌលសុខភាពផ្តល់ការបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តផ្នែកសុខភាពសហគមន៍ សម្រាប់សេវាកម្មព្យាបាលសុខភាពឱ្យបានទូលំទូលាយ ។ | ពុះពារលើការគំរាមកំហែងដោយការប្រើប្រាស់ភាពខ្លាំង<br>១. ក្រសួងសុខាភិបាល ចាប់ផ្តើមយុទ្ធនាការស្តីពីសុខភាពកុមារ ដើម្បីលើកកម្ពស់ចំណេះដឹងរបស់ឪពុកម្តាយ ដោយប្រើមណ្ឌលសុខភាព អ្នកស្ម័គ្រចិត្តផ្នែកសុខភាព និងប្រព័ន្ធផ្សព្វផ្សាយដូចជាវិទ្យុ។ |
| ភាពខ្សោយ<br>១. ថវិកាគាំទ្រដោយរដ្ឋាភិបាលនៅមានកម្រិតទាប<br>២. កម្មវិធីផ្តល់សេវាចាក់ថ្នាំបង្ការរោគ មិនបានគ្រប់គ្រាន់នៅតំបន់ជនបទ ដោយសារធនធានមនុស្សនៅមានកម្រិត។ | ប្រើប្រាស់ឱកាសដោយកាត់បន្ថយភាពខ្សោយ<br>១. អ្នកស្ម័គ្រចិត្តផ្នែកសុខភាពសហគមន៍ដែលបានបណ្តុះបណ្តាល ជួយមណ្ឌលសុខភាពនៅក្នុងកម្មវិធីសេវាសុខភាពក្រៅមន្ទីរពេទ្យ នៅតំបន់ដាច់ស្រយាល (ឧទាហរណ៍៖ ការចាក់ថ្នាំបង្ការ ថ្លឹងទម្ងន់ ផ្តល់ចំណេះដឹងដល់ម្តាយ)។<br>២. ក្រសួងសុខាភិបាលចាប់ផ្តើមអនុវត្តគម្រោងមួយ "*គម្រោងស្តីពីឱសថស្ថាន*" ដែលដំណើរការដោយអ្នកស្ម័គ្រចិត្តផ្នែកសុខភាពសហគមន៍ដើម្បីរកថវិកា និងប្រាក់ឧបត្ថម្ភ ។ | ពុះពារលើការគំរាមកំហែងដោយកាត់បន្ថយភាពខ្សោយ |

**ឧបសម្ព័ន្ធ ២.៤ វិធីសាស្ត្រដាក់ពិន្ទុសម្រាប់ចាត់អាទិភាព**

"*វិធីសាស្ត្រដាក់ពិន្ទុសម្រាប់ចាត់អាទិភាព*" នឹងប្រើប្រាស់ដើម្បីពិភាក្សា និងចាត់អាទិភាព ក )បញ្ហា និងមូលហេតុដើម្បីរៀបចំការវិភាគស្ថានភាព និងខ )គោលបំណង គោលដៅ និងដំណោះស្រាយសម្រាប់រៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ ជាពិសេសនៅពេលដែលបញ្ហា មូលហេតុ គោលបំណង និងគោលដៅ ព្រមទាំងដំណោះស្រាយ ត្រូវបានកំណត់យ៉ាងច្រើន។

ក្នុងស្ថានភាពជាក់ស្តែង រាជធានី ខេត្តមានធនធានមានកម្រិតដូចជា ថវិកា និងធនធានមនុស្ស ដើម្បីសម្រេចគោលបំណង និងគោលដៅក្នុងរយៈពេលប្រាំ(០៥)ឆ្នាំ (ឧទាហរណ៍៖ ក្របខ័ណ្ឌពេលវេលានៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ)។

ជាគោលការណ៍ អ្នកពាក់ព័ន្ធត្រូវព្យាយាមកម្រិតចំនួនបញ្ហា និងមូលហេតុ ដោយផ្អែកលើការចូលរួមពិភាក្សាដើម្បីបញ្ចៀសនូវស្ថានភាពដែលផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំត្រូវរៀបចំឡើង ដោយមិនមានភាពប្រាកដប្រជា។

ជាញឹកញាប់ ការកំណត់ថាតើបញ្ហាមួយណាមានសារៈសំខាន់ជាងគេការលំបាក ដោយសារតែបញ្ហាដែលបានលើកឡើងតែងតែមានអ្នកគាំទ្រ។ ហេតុដូចនេះ*វិធីសាស្ត្រដាក់ពិន្ទុសម្រាប់ចាត់អាទិភាព*អាចណែនាំឱ្យប្រើប្រាស់ជាវិធីសាស្ត្របំពេញបន្ថែមក្នុងការពិភាក្សា និងឯកភាពគ្នា។ វិធីសាស្ត្រដាក់ពិន្ទុនេះ នឹងត្រូវប្រើប្រាស់ក្នុងកិច្ចប្រជុំសម្រាប់ការពិភាក្សា និងឯកភាពក្នុងការវិភាគស្ថានភាព ។

១. អ្នកពាក់ព័ន្ធនឹងពិភាក្សាលើផ្នែកនីមួយៗក្នុងការរៀបចំបញ្ជីបញ្ហា ។
២. អ្នកពាក់ព័ន្ធត្រូវពិភាក្សា និងបោះឆ្នោតជ្រើសរើសយកបញ្ហា នៅពេលដែលការឯកភាពគ្នាមានការលំបាក។

| បញ្ហា/មូលហេតុ | សមហេតុផល | ពេលវេលា | ភាពដែលអាចធ្វើទៅបាន | ផលប៉ះពាល់ | សរុប |
|---|---|---|---|---|---|
| ក | ៣ | ៥ | ២ | ២ | ១២ |
| ខ | ៣ | ៤ | ៣ | ១ | ១១ |
| គ | ៣ | ៣ | ៥ | ៣ | ១៤ |

**សម្គាល់៖** ពិន្ទុអាចដាក់ពី ១(ទាបបំផុត)ទៅ ៥(ខ្ពស់បំផុត)

អ្នកពាក់ព័ន្ធអាចជ្រើសរើសយកលក្ខណៈវិនិច្ឆ័យផ្សេងទៀត បន្ថែមលើឧទាហរណ៍ខាងលើ។

| លក្ខណៈវិនិច្ឆ័យ | បរិយាយ |
|---|---|
| **សមហេតុផល** | ▪ ពិនិត្យថាតើបញ្ហា និងមូលហេតុភ្ជាប់ទំនាក់ទំនងគ្នាដោយសមហេតុផលដែរឬទេ។<br>▪ ករណីដែលចំណុចខាងលើមិនបានភ្ជាប់ទំនាក់ទំនងគ្នាដោយសមហេតុផលនោះទេ លទ្ធភាពដើម្បីទទួលបានសមិទ្ធផលមានកម្រិតទាប។ |
| **ពេលវេលា** | ▪ បញ្ហាដែលលើកឡើង ត្រូវតែដោះស្រាយក្នុងរយៈពេល៥ឆ្នាំ។ ករណីដែលបញ្ហានោះត្រូវចំណាយពេលច្រើនជាងប្រាំឆ្នាំ ទំហំបញ្ហាត្រូវបង្រួមឱ្យតូច។ |
| **ភាពដែលអាចធ្វើទៅបាន** | ▪ ភាពដែលអាចធ្វើទៅបាន អាចពិចារណាក្នុងទស្សនៈបច្ចេកទេស (ឧទាហរណ៍៖ ថាតើរាជធានី ខេត្ត មានសមត្ថភាពខាងបច្ចេកទេស ហិរញ្ញវត្ថុ(តម្លៃចាំបាច់ដែលរំពឹងទុក) និងធនធានមនុស្ស(ចំនួនធនធានមនុស្សដែលចាំបាច់) គ្រប់គ្រាន់ឬនៅ។ |

<table>
<tr><td><u>ផលប៉ះពាល់</u></td><td>▪ ផលប៉ះពាល់គួរត្រូវប៉ាន់ស្មានក្នុងលក្ខខណ្ឌទំហំនៃអត្ថប្រយោជន៍វិជ្ជមានដូចជាចំនួនអ្នកទទួលផល និងការកើនឡើងចំណូលដែលបានរំពឹងទុក ។ល។<br>▪ ការកំណត់ផលប៉ះពាល់ជាក់លាក់ អាចមានការលំបាក ដូច្នេះការប៉ាន់ស្មានផលប៉ះពាល់ប្រហាក់ប្រហែល គឺអាចទទួលយកបាន។</td></tr>
<tr><td colspan="2">៣. អ្នកពាក់ព័ន្ធដែលពិភាក្សាលើផ្នែកនីមួយៗ ជ្រើសរើសបញ្ហាអាទិភាពដោយផ្អែកលើលទ្ធផលនៃការពិភាក្សា និងបោះឆ្នោតសម្រាប់វិធីសាស្ត្រដាក់ពិន្ទុ។</td></tr>
</table>

ដោយខុសគ្នាពីកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់រាជធានី ខេត្ត បញ្ជីបញ្ហា /មូលហេតុក្នុងផែនការអភិវឌ្ឍន៍មិនមានទិន្នន័យជាតួលេខដូចជាតម្លៃគម្រោង ឬចំនួនអ្នក ទទួលផលទេ។ ហេតុនេះ "*វិធីសាស្ត្រដាក់ពិន្ទុសម្រាប់ចាត់អាទិភាព*" លើបញ្ហាមានការលំបាកសម្រាប់ប្រើប្រាស់។ ដូច្នេះ វិធីសាស្ត្រដាក់ពិន្ទុគួរត្រូវប្រើប្រាស់ជាវិធីសាស្ត្របំពេញបន្ថែមសម្រាប់ការពិភាក្សា និងឯកភាព។

**ឧបសម្ព័ន្ធ ២.៥ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

**១) វិធីសាស្ត្រ**

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវអនុវត្តកិច្ចការសំខាន់ៗចំនួន៣ រួមមាន៖**ក.ពិនិត្យ ខ.វិភាគ និង គ.អនុវត្ត**។

ក. ពិនិត្យវឌ្ឍនភាពនៃការសម្រេចបានគោលបំណង គោលដៅ និងដំណោះស្រាយតាមរយៈការទទួលបានទិន្នន័យសូចនាករ។

ខ. វិភាគ ខ.១)ថាតើកម្រិតសមិទ្ធផលដែលសម្រេចបាន សមស្របឬទេ អំឡុងពេលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ខ.២)កត្តាវិជ្ជមានដែលរួមចំណែកដល់ការសម្រេចបានសមិទ្ធផល និងខ.៣)កត្តាអវិជ្ជមានដែលរាំងស្ទះដល់ការសម្រេចបានសមិទ្ធផលពីផ្នែកមួយចំនួនដូចខាងក្រោម។

- ផ្នែកបច្ចេកទេស (ពិនិត្យថាតើបច្ចេកទេសសមស្រប មានហើយឬនៅ)
- ផ្នែកហិរញ្ញវត្ថុ(ពិនិត្យថាតើធនធានហិរញ្ញវត្ថុប្រើប្រាស់អស់លទ្ធភាព និងទាន់ពេលវេលាហើយឬនៅ)
- ផ្នែកធនធានមនុស្ស (ពិនិត្យថាតើចំនួន និងជំនាញធនធានមនុស្សត្រូវប្រើប្រាស់អស់លទ្ធភាពហើយឬនៅ)
- ផ្នែកស្ថាប័ន (ពិនិត្យថាតើស្ថាប័នទទួលបន្ទុកអនុវត្តសកម្មភាពចាំបាច់ក្នុងពេលវេលាសមស្របដែរឬទេ

គ. អនុវត្តសកម្មភាពកែតម្រូវ ឬការផ្លាស់ប្តូរទំហំគោលបំណង គោលដៅ និងដំណោះស្រាយដល់លទ្ធផលដែលមិនសម្រេចបាន និង/ឬការពន្យារពេលសម្រេចបាននូវលទ្ធផល។

**២) ទម្រង់នៃរបាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ទម្រង់របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍វាយតម្លៃត្រូវមានចំណុចសំខាន់ៗចំនួន៣ ដោយផ្អែកលើវិធីសាស្ត្រការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖ ក)សមិទ្ធផល ខ)ការវាយតម្លៃ និងគ)អនុសាសន៍។

**ជំពូកទី១÷ សេចក្តីផ្តើម**

ជំពូកទី១ ត្រូវរៀបរាប់អំពីព័ត៌មានទូទៅស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដូចជាកាលវិភាគ និងស្ថាប័នទទួលបន្ទុកជាដើម។

**ជំពូកទី២÷ សមិទ្ធផល និងការវិភាគ**

ជំពូកទី២ ត្រូវភ្ជាប់តារាងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលមានទិន្នន័យបច្ចុប្បន្នភាពចុងក្រោយក្នុងកូឡោនសូចនាករ។ ក្នុងតារាងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក៏ត្រូវធ្វើការវិភាគពីផ្នែកនីមួយៗ ផងដែរ។

ក. ផ្នែកសេដ្ឋកិច្ច ដោយមានទិន្នន័យតាមដាន ត្រួតពិនិត្យ

ខ. ផ្នែកសង្គមកិច្ច ដោយមានទិន្នន័យតាមដាន ត្រួតពិនិត្យ

គ. ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានមនុស្ស បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយដោយមានទិន្នន័យតាមដាន ត្រួតពិនិត្យ

ឃ. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដោយមានទិន្នន័យតាមដាន ត្រួតពិនិត្យ

**ជំពូកទី៣÷ អនុសាសន៍**

**(ការតាមដាន ត្រួតពិនិត្យនៅឆ្នាំទី១ ដល់ឆ្នាំទី៤)**

អនុសាសន៍ត្រូវមានវិធានការកែលម្អសម្រាប់ផ្នែកនីមួយៗ។

**(ការវាយតម្លៃនៅឆ្នាំទី៥)**

បទពិសោធន៍សិក្សាមួយចំនួនស្តែងចេញពីការអនុវត្ត CPDP កន្លងមក ទោះជាលទ្ធផលល្អ ឬមិនល្អក៏ដោយ ត្រូវពន្យល់ក្នុងនៅទីនេះ សម្រាប់ជាបទពិសោធន៍ក្នុងការកសាង CPDP នៅអាណត្តិក្រោយ ។

**៣) ភាពខុសគ្នារវាងរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍វាយតម្លៃបញ្ចប់អាណត្តិ**

ខាងក្រោមនេះ ពន្យល់ពីភាពខុសគ្នាមួយចំនួនរវាង ក )ការតាមដាន ត្រួតពិនិត្យនឹងរៀបចំនៅចុងឆ្នាំទី១ ទី២ ទី៣ និងទី៤ ហើយ ខ)ការវាយតម្លៃបញ្ចប់អាណត្តិនឹងរៀបចំនៅចុងឆ្នាំទី៥ របស់ក្រុមប្រឹក្សា។

| ការតាមដាន ត្រួតពិនិត្យនៅឆ្នាំទី១ ដល់ឆ្នាំទី៤ | ការវាយតម្លៃបញ្ចប់អាណត្តិនៅឆ្នាំទី៥ |
|---|---|
| ▪ ពិនិត្យទិន្នន័យជារៀងរាល់ឆ្នាំ(១ឆ្នាំម្តង)<br>▪ វាយតម្លៃសមិទ្ធផលជារៀងរាល់ឆ្នាំ | ▪ ពិនិត្យទិន្នន័យឆ្នាំទី៥<br>▪ ពិនិត្យទិន្នន័យឆ្នាំទី១ ដល់ឆ្នាំទី៤<br>▪ វាយតម្លៃសមិទ្ធផលឆ្នាំទី៥<br>▪ វាយតម្លៃសមិទ្ធផលទាំងមូលក្នុងរយៈពេលប្រាំឆ្នាំ |

ផ្អែកលើតារាងខាងលើ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃចាប់ពីឆ្នាំទី១ ដល់ឆ្នាំទី៤ ពិនិត្យទៅលើតែសមិទ្ធផលនៅឆ្នាំនីមួយៗ រីឯការវាយតម្លៃបញ្ចប់អាណត្តិនៅឆ្នាំទី៥ ពិនិត្យទៅលើ ក )សមិទ្ធផលនៅឆ្នាំទី៥ និង ខ )សមិទ្ធផលទាំងមូលក្នុងរយៈពេលប្រាំឆ្នាំ។

# ឧបសម្ព័ន្ធ ៣៖ ប្រតិទិនការងារសម្រាប់ការកសាងផែនការ

## ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត

| ល.រ | សកម្មភាព | ពេលវេលា | ទីតាំង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| **ជំហានទី១៖ ការរៀបចំ និងការផ្សព្វផ្សាយព័ត៌មានស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** | | | | | | |
| ១.១ | ការរៀបចំឯកសារ និងព័ត៌មាន | | | | | |
| ១.១.១ | ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ១.១.២ | ការរៀបចំតារាងវិភាគស្ថានភាពរាជធានី ខេត្ត | | | | | |
| ១.១.៣ | ការរៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សារាជធានី ខេត្ត | | | | | |
| ១.១.៤ | ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា | | | | | |
| ១.២ | កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| **ជំហានទី២៖ ការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត** | | | | | | |
| ២.១ | កិច្ចប្រជុំវិភាគស្ថានភាពរាជធានី ខេត្ត និងការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ២.២ | ការពិនិត្យ កែសម្រួល និងអនុម័តក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ២.៣ | ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម | | | | | |
| ២.៤ | ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | |
| ២.៤.១ | ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ CPDP | | | | | |
| ២.៤.២ | ការរៀបចំនិតិវិធីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តន៍ CPIP | | | | | |
| ២.៥ | ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ២.៦ | កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ២.៧ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ២.៨ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស<br>លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| **ជំហានទី៣៖ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍រាជធានីខេត្ត** | | | | | | |
| ៣.១ | ការអនុម័តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ៣.១.១ | ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត | | | | | |
| ៣.១.២ | កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត | | | | | |
| ៣.១.៣ | ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត | | | | | |
| ៣.២ | ការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ៣.២.១ | ការបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |
| ៣.២.២ | ការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |

## ប្រតិទិនការងារសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

| ល.រ | សកម្មភាព | ពេលវេលា | ទីតាំង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| **ជំហានទី១÷ ការរៀបចំគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត** | | | | | | |
| ១.១ | ការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច | | | | | |
| ១.២ | កិច្ចប្រជុំណែនាំដើម្បីកំណត់ និងរៀបចំសំណើគម្រោងវិនិយោគ | | | | | |
| ១.៣ | ការពិនិត្យសំណើគម្រោងវិនិយោគ | | | | | |
| ១.៤ | កិច្ចប្រជុំពិនិត្យតារាងបូកសរុបសំណើគម្រោងវិនិយោគ | | | | | |
| **ជំហានទី២÷ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត** | | | | | | |
| ២.១ | ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត | | | | | |
| ២.២ | ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត | | | | | |
| ២.៣ | សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត | | | | | |
| ២.៤ | ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគរាជធានី ខេត្ត | | | | | |
| ២.៥ | ការរៀបចំក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | |
| ២.៦ | ការរៀបចំបញ្ចប់សេចក្តីព្រាងចុងក្រោយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត | | | | | |
| ២.៧ | ការពិនិត្យនិងផ្តល់យោបល់របស់គណៈអភិបាលរាជធានី ខេត្តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត | | | | | |
| ២.៨ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសលើសេចក្តីព្រាង<br>កម្មវិធីវិនិយោគរាជធានី ខេត្ត | | | | | |
| **ជំហានទី៣ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគរាជធានីខេត្ត** | | | | | | |
| ៣.១ | ការអនុម័តកម្មវិធីវិនិយោគរាជធានី ខេត្ត | | | | | |
| ៣.១.១ | ការងារមុនកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត | | | | | |
| ៣.១.២ | កិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត | | | | | |
| ៣.១.៣ | ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត | | | | | |
| ៣.២ | ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍រាជធានី ខេត្ត | | | | | |

ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ខាងលើត្រូវបានក្រុមប្រឹក្សារាជធានី ខេត្ត.................... អនុម័តក្នុងកិច្ចប្រជុំ..................លើកទី.........នាថ្ងៃទី.......ខែ....ឆ្នាំ.......។

ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត

## ឧបសម្ព័ន្ធ ៤៖ ព័ត៌មានសំខាន់ៗស្តីពីស្ថានភាពរាជធានី ខេត្ត

| បរិយាយ | ឯកតា | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ |
|---|---|---|---|---|---|
| **ទិន្នន័យទូទៅ** | | | | | |
| ផ្ទៃដីរាជធានី ខេត្ត | | | | | |
| ចំនួនក្រុងស្រុកខណ្ឌ | | | | | |
| ចំនួនឃុំសង្កាត់ | | | | | |
| ចំនួនភូមិ | | | | | |
| ចំនួនប្រជាជន | | | | | |
| ចំនួនគ្រួសារ | | | | | |
| ទំហំគ្រួសារជាមធ្យម | | | | | |
| ដង់ស៊ីតេប្រជាជន | | | | | |
| កំណើនប្រជាជន | | | | | |
| ភាគរយគ្រួសារក្រីក្រ | | | | | |
| ........ | | | | | |
| **ទិន្នន័យផ្នែកសេដ្ឋកិច្ច** | | | | | |
| **ភាគរយគ្រួសារមានមុខរបរជាចម្បង៖** | | | | | |
| ធ្វើស្រែ | | | | | |
| ការដាំដំណាំ | | | | | |
| នេសាទ | | | | | |
| ការចិញ្ចឹមសត្វ | | | | | |
| ....... | | | | | |
| **ភាគរយគ្រួសារមានមុខរបរធ្វើសិប្បកម្មជាចម្បង៖** | | | | | |
| សិប្បកម្មផលិតគ្រឿងសង្ហារឹម | | | | | |
| សិប្បកម្មតម្បាញរវៃក្រមា ហូល... | | | | | |
| ........... | | | | | |
| **ភាគរយគ្រួសារមានមុខរបរសេវាកម្មជាចម្បង៖** | | | | | |
| មុខរបរជំនួញ | | | | | |
| មុខរបរជាង | | | | | |
| សេវាទេសចរណ៍ | | | | | |
| ........ | | | | | |
| **ទិន្នន័យសង្គមកិច្ច** | | | | | |
| ភាគរយកុមារអាយុ ៣៥ឆ្នាំចូលរៀនក្នុងមត្តេយ្យសាលា | | | | | |
| ភាគរយកុមារអាយុ ៦១១ឆ្នាំចូលរៀនក្នុងបឋមសិក្សា | | | | | |
| ភាគរយកុមារអាយុ ១៥-១៧ឆ្នាំមិនបានចូលរៀន | | | | | |

| បរិយាយ | ឯកតា | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ |
|---|---|---|---|---|---|
| ភាគរយអ្នកមិនចេះអក្សរសរុបអាយុពី១៥-៦០ឆ្នាំ | | | | | |
| ភាគរយស្ត្រីសម្រាលកូនដោយឆ្មបបុរាណ | | | | | |
| អត្រាមរណភាពមាតាក្រោយពេលសម្រាលកូន(០-១ខែ) ក្នុង ១០០.០០០កំណើត | | | | | |
| អត្រាមរណភាពទារកអាយុ(០-១២)ខែក្នុង ១០០០កំណើតរស់ | | | | | |
| ភាគរយកុមារអាយុ ០-២ឆ្នាំមិនបានចាក់ថ្នាំបង្ការគ្រប់ចំនួន | | | | | |
| ភាគរយគ្រួសារប្រើប្រាស់ទឹកពីប្រភពទឹកស្អាតនៅរដូវប្រាំង | | | | | |
| ភាគរយគ្រួសារប្រើប្រាស់ទឹកពីប្រភពមិនស្អាតនៅរដូវប្រាំង | | | | | |
| ភាគរយគ្រួសារមានបង្គន់អនាម័យ | | | | | |
| ................. | | | | | |
| **ទិន្នន័យផ្នែកដីធ្លីធនធានធម្មជាតិ និងបរិស្ថាន** | | | | | |
| ចំនួនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ | | | | | |
| ចំនួនជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ | | | | | |
| ចំនួនគ្រួសារមានសេវាប្រមូលសំរាម | | | | | |
| ចំនួនគ្រួសារទទួលរងនូវការបំពុលបរិស្ថាន | | | | | |
| គ្រួសារដាំដុះដោយប្រើជីគីមី | | | | | |
| គ្រោះទឹកជំនន់ដែលកើតមានឡើង | | | | | |
| គ្រោះរាំងស្ងួតដែលកើតមានឡើង | | | | | |
| គ្រោះអគ្គីភ័យដែលកើតមានឡើង | | | | | |
| ........... | | | | | |
| **ទិន្នន័យផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់** | | | | | |
| ភាគរយទារកមិនបានចុះសំបុត្រកំណើតក្នុងឆ្នាំ | | | | | |
| ចំនួនគ្រួសារមានផ្ទះនៅលើដីសាធារណៈ | | | | | |
| ចំនួនជនអនាថាគ្មានទីពឹង | | | | | |
| ចំនួនជនរងគ្រោះដោយសារការរំលោភផ្លូវភេទ | | | | | |
| ចំនួនជនរងគ្រោះដោយសារការជួញដូរមនុស្ស | | | | | |
| ចំនួនករណីលួច | | | | | |
| ចំនួនករណីទំនាស់ដីធ្លី | | | | | |
| ចំនួនគ្រួសារមានអំពោះហិង្សាក្នុងគ្រួសារ | | | | | |
| ចំនួនករណីគ្រោះថ្នាក់ចរាចរណ៍ | | | | | |
| ............... | | | | | |

## **ឧបសម្ព័ន្ធ ៥៖ តារាងគំរូ**

## ឧបសម្ព័ន្ធ ៥.១. តារាងវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

អង្គភាពស្នើ៖_______________ កាលបរិច្ឆេទ៖_______________

| បញ្ហា | មូលហេតុ | តម្រូវការយេនឌ័រ |
|---|---|---|
| **ផ្នែកសេដ្ឋកិច្ច** | | |
| | | |
| | | |
| **ផ្នែកសង្គមកិច្ច** | | |
| | | |
| | | |
| **ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ** | | |
| | | |
| | | |
| **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | |
| | | |
| | | |

## ឧបសម្ព័ន្ធ ៥.២. តារាងបូកសរុបការវិភាគស្ថានភាពរបស់អ្នកពាក់ព័ន្ធ

កាលបរិច្ឆេទ៖______________

| បញ្ហា | មូលហេតុ | តម្រូវការយេនឌ័រ |
|---|---|---|
| **ផ្នែកសេដ្ឋកិច្ច** | | |
| | | |
| | | |
| **ផ្នែកសង្គមកិច្ច** | | |
| | | |
| | | |
| **ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ** | | |
| | | |
| | | |
| **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | |
| | | |
| | | |

## ឧបសម្ព័ន្ធ ៥.៣. តារាងវិភាគស្ថានភាពរាជធានីខេត្តដែលបានចាត់អាទិភាព

កាលបរិច្ឆេទ៖_______________

| បញ្ហា | មូលហេតុ | គម្រូវការយេនឌ័រ |
|---|---|---|
| **ផ្នែកសេដ្ឋកិច្ច** | | |
| | | |
| | | |
| **ផ្នែកសង្គមកិច្ច** | | |
| | | |
| | | |
| **ផ្នែកការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ** | | |
| | | |
| | | |
| **ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | |
| | | |
| | | |

## ឧបសម្ព័ន្ធ ៥.៤. តារាងក្របខ័ណ្ឌអភិវឌ្ឍន៍រាជធានី ខេត្ត

<table>
<tr><td colspan="8">ចក្ខុវិស័យ÷</td></tr>
<tr><td colspan="8">១. ផ្នែកសេដ្ឋកិច្ច</td></tr>
<tr><td rowspan="2">គោលបំណង&គោលដៅ</td><td rowspan="2">ដំណោះស្រាយ</td><td colspan="4">សូចនាករ</td><td rowspan="2">អង្គភាពទទួលខុសត្រូវ</td><td rowspan="2">ប្រភពទិន្នន័យ</td></tr>
<tr><td>បរិយាយសង្ខេប</td><td>ឯកតា</td><td>២០១៨<br>(បច្ចុប្បន្ន)</td><td>២០១៩<br>(គោលដៅ)</td></tr>
<tr><td colspan="8">គោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច</td></tr>
<tr><td colspan="8">យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច</td></tr>
<tr><td>១. គោលបំណង<br>១.១ គោលដៅ<br><br><br>១.២ គោលដៅ</td><td>១.១.១ ដំណោះស្រាយ<br>១.១.២ ដំណោះស្រាយ<br><br>១.២.១ ដំណោះស្រាយ<br>១.២.២ ដំណោះស្រាយ</td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td>២. គោលបំណង<br>២.១ គោលដៅ<br><br><br>២.២ គោលដៅ</td><td>២.១.១ ដំណោះស្រាយ<br>២.១.២ ដំណោះស្រាយ<br><br>២.២.១ ដំណោះស្រាយ<br>២.២.២ ដំណោះស្រាយ</td><td></td><td></td><td></td><td></td><td></td><td></td></tr>
</table>

| ២. ផ្នែកសង្គមកិច្ច | | | | | | | |
|---|---|---|---|---|---|---|---|
| គោលបំណង&គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៨ (បច្ចុប្បន្ន) | ២០១៩ (គោលដៅ) | | |
| គោលបំណងអភិវឌ្ឍន៍សង្គមកិច្ច | | | | | | | |
| យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច | | | | | | | |
| ១. គោលបំណង<br>១.១ គោលដៅ<br><br><br>១.២ គោលដៅ | <br>១.១.១ ដំណោះស្រាយ<br>១.១.២ ដំណោះស្រាយ<br><br>១.២.១ ដំណោះស្រាយ<br>១.២.២ ដំណោះស្រាយ | | | | | | |
| ២. គោលបំណង<br>២.១ គោលដៅ<br><br><br>២.២ គោលដៅ | <br>២.១.១ ដំណោះស្រាយ<br>២.១.២ ដំណោះស្រាយ<br><br>២.២.១ ដំណោះស្រាយ<br>២.២.២ ដំណោះស្រាយ | | | | | | |

| ៣.ផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | | | | | |
|---|---|---|---|---|---|---|---|
| គោលបំណង&គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៨ (បច្ចុប្បន្ន) | ២០១៩ (គោលដៅ) | | |
| គោលបំណងការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | | | | | |
| យុទ្ធសាស្ត្រការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | | | | | |
| ១. គោលបំណង<br>១.១ គោលដៅ<br><br>១.២ គោលដៅ | ១.១.១ ដំណោះស្រាយ<br>១.១.២ ដំណោះស្រាយ<br>១.២.១ ដំណោះស្រាយ<br>១.២.២ ដំណោះស្រាយ | | | | | | |
| ២. គោលបំណង<br>២.១ គោលដៅ<br><br>២.២ គោលដៅ | ២.១.១ ដំណោះស្រាយ<br>២.១.២ ដំណោះស្រាយ<br>២.២.១ ដំណោះស្រាយ<br>២.២.២ ដំណោះស្រាយ | | | | | | |

| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | |
|---|---|---|---|---|---|---|---|
| គោលបំណង&គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៨ (បច្ចុប្បន្ន) | ២០១៩ (គោលដៅ) | | |
| គោលបំណងគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | |
| យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | |
| ១. គោលបំណង<br>១.១ គោលដៅ<br><br>១.២ គោលដៅ | ១.១.១ ដំណោះស្រាយ<br>១.១.២ ដំណោះស្រាយ<br><br>១.២.១ ដំណោះស្រាយ<br>១.២.២ ដំណោះស្រាយ | | | | | | |
| ២. គោលបំណង<br>២.១ គោលដៅ<br><br>២.២ គោលដៅ | ២.១.១ ដំណោះស្រាយ<br>២.១.២ ដំណោះស្រាយ<br><br>២.២.១ ដំណោះស្រាយ<br>២.២.២ ដំណោះស្រាយ | | | | | | |

# ឧបសម្ព័ន្ធ ៥.៥. តារាងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

| **១. ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ១.១. គោលបំណង<br>១.១.១ គោលដៅ<br><br><br>១.១.២ គោលដៅ | <br>១.១.១.១ ដំណោះស្រាយ<br>១.១.១.២ ដំណោះស្រាយ<br><br>១.១.២.១ ដំណោះស្រាយ<br>១.១.២.២ ដំណោះស្រាយ | | | | | | | | | | |
| ១.២. គោលបំណង<br>១.២.១ គោលដៅ<br><br><br>១.២.២ គោលដៅ | <br>១.២.១.១ ដំណោះស្រាយ<br>១.២.១.២ ដំណោះស្រាយ<br><br>១.២.២.១ ដំណោះស្រាយ<br>១.២.២.២ ដំណោះស្រាយ | | | | | | | | | | |

## ២. ផ្នែកសង្គមកិច្ច

| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ២.១. គោលបំណង | | | | | | | | | | | | |
| ២.២. គោលបំណង | | | | | | | | | | | | |

## ៣. ផ្នែកការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ៣.១. គោលបំណង | | | | | | | | | | | | |
| ៣.២. គោលបំណង | | | | | | | | | | | | |

## ៤. ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

| គោលបំណង & គោលដៅ | ដំណោះស្រាយ | សូចនាករ | | | | | | | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បរិយាយសង្ខេប | ឯកតា | ២០១៤ (បច្ចុប្បន្ន) | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៩ (គោលដៅ) | | |
| ៤.១. គោលបំណង | | | | | | | | | | | | |
| ៤.២. គោលបំណង | | | | | | | | | | | | |

## ឧបសម្ព័ន្ធ៦៖ សេចក្ដីណែនាំបច្ចេកទេសស្ដីពីការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត